**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តបាត់ដំបង**
សំណុំរឿងព្រហ្មទណ្ឌ
លេខ៖៣៤៦/២៤-០៤-១៩
សំណុំរឿងជំនុំជម្រះ
លេខ៖ ៨៨២/០៩-០៩-២០
សាលក្រមព្រហ្មទណ្ឌ
លេខ៖១៨១៦"ក"/២៨-១២-២០

# តាងនាមប្រជារាស្ត្រខ្មែរ

# សាលាដំបូងខេត្តបាត់ដំបង

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តបាត់ដំបង និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ ត្រូវនឹងថ្ងៃចន្ទ ១៤ កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព-ស ២៥៦៤ ដែលមានសមាសភាពដូចតទៅ ៖

## ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

ឯកឧត្តម [redacted] ប្រធានសាលាដំបូងខេត្តបាត់ដំបង

## ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមសាលាដំបូងខេត្តបាត់ដំបង

លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តបាត់ដំបង

## តំណាងអយ្យការ

ឯកឧត្តម [redacted] ព្រះរាជអាជ្ញា

នៃអយ្យការអមសាលាដំបូងខេត្តបាត់ដំបង

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តបាត់ដំបង

ដើម្បីជំនុំជម្រះលើបណ្តឹងទាស់នឹងសាលក្រមព្រហ្មទណ្ឌលេខ ១១៧២ "ក" ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០ របស់លោក [redacted]នធឿន ជាមេធាវីការពារសិទ្ធិឱ្យពិរុទ្ធជនឈ្មោះ [redacted] ឧត្តម ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២០ ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៣៤៦ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ ២០១៩ ដែលមានពិរុទ្ធជន ៖

-ឈ្មោ[redacted] ឧត្តម **ហៅ** ហុង ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅភូមិស្ពានកណ្តោល ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង សាសនាព្រះពុទ្ធ មុខរបរនៅផ្ទះ មានទីលំនៅ [redacted] ស្រុកបវេល ខេត្តបាត់ដំបង ប្រពន្ធឈ្មោះ [redacted] (លែងលះ) ឪពុកឈ្មោះ [redacted] (រស់) ម្តាយឈ្មោះ [redacted] (រស់) កម្រិតវប្បធម៌ថ្នាក់ទី១២ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។ (គេចខ្លួន)

**-ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ៨៦៨ ត-ព្រ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០ ។**

-ជាប់ចោទពីបទ " ប៉ុនប៉ងរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ " តាមបញ្ញត្តិមាត្រា ២៧ និងមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចភូមិបវេល១ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៧ ។

-លោក [redacted] ប៊ុនធឿន អត្តលេខ ១៥៩ ជាមេធាវីការពារសិទ្ធិឱ្យពិរុទ្ធជនឈ្មោះ [redacted] ឧត្តម ហៅ ហុង ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សីហា ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិបវេល១ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង ។

-ជនរងគ្រោះឈ្មោះ [redacted] គីមហុង ភេទស្រី អាយុ១៤ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន [redacted] ខេត្តបាត់ដំបង ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ២២៣៤ ដស-សព ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង ។

-បានឃើញដីកាដំណោះស្រាយលេខ ៧៨៨ ដ-ជ-រ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបាត់ដំបង ។

-បានឃើញដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខ ៧៣៧៣ ត-ព្រ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ របស់ប្រធានសាលាដំបូងខេត្តបាត់ដំបង ។

-បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១១៧២ "ក" ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តបាត់ដំបង ។

-បានឃើញពាក្យបណ្តឹងទាស់ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៧ របស់លោកមេធាវី [redacted] ប៊ុនធឿន ។

## **ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅៈ**

កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៧ វេលាម៉ោង៤និង៣០នាទី ទាបភ្លឺ នៅចំណុចភូមិបវេល១ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង ជនជាប់ចោទឈ្មោះ [redacted] ឧត្តម ភេទប្រុស អាយុ ២១ឆ្នាំ បានធ្វើសកម្មភាពប៉ុនប៉ងរំលោភប្អូនថ្លៃស្រីរបស់ខ្លួនឈ្មោះ [redacted] គីមហុង អាយុ១៤ឆ្នាំ ដែលនាងកំពុងគេងនៅក្នុងបន្ទប់តែម្នាក់ឯង ព្រោះថាពេលនោះឪពុកម្តាយ និងជីដូន បានក្រោកទៅហែទានវស្សាអស់ ។ ដោយឃើញដូច្នេះ ឈ្មោះ [redacted] ឧត្តម បានចូលទៅក្នុងបន្ទប់ប្អូនថ្លៃឈ្មោះ [redacted] គីមហុង ពេលនាងកំពុងគេងលក់ ហើយបានធ្វើសកម្មភាពសម្រាតខោអាវរបស់ប្អូនថ្លៃដល់ត្រឹមជង្គង់ ប៉ុន្តែត្រូវឈ្មោះ [redacted] គីមហុង ដាក់ចំប្រដាប់ភេទជនជាប់ចោទ និងរើបំរាស់ តែត្រូវឈ្មោះ [redacted] ឧត្តម ចាប់ទាញ់សក់ឱ្យគេងលើពូកវិញ ហើយបានយកខ្នើយមកខ្ទប់មាត់ ពេលនោះឈ្មោះ [redacted] គីមហុង ខំរើបំរាស់ម្តងទៀត ដោយយកជើងធាក់ចំឈ្មោះ [redacted] ឧត្តម បណ្តាលឱ្យចុកហួល ហើយឈ្មោះ [redacted] ឧត្តម បានងើបដើរចេញ ដោយបានគំរាមថា បើប្រាប់ប៉ាម៉ាក់ឱ្យដឹង នឹងមានរឿងហើយ ។

35/4

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ឧត្តម វត្តមាន ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សីហា វត្តមាន ជនរងគ្រោះឈ្មោះ គ្រី គីមហុង វត្តមាន សាក្សីឈ្មោះ រស់ ស្រីពៅ អវត្តមាន សាក្សីឈ្មោះ [redacted] គីមហៀច អវត្តមាន ។

-ជនជាប់ចោទឈ្មោះ [redacted] ឧត្តម បានឆ្លើយថា ៖ ខ្លួនមានទីលំនៅស្រុកបវេល ។ កន្លងមក ខ្លួនធ្លាប់បានទទួលដីកាកោះរបស់តុលាការ ហើយខ្លួនក៏ធ្លាប់ចូលមកឆ្លើយដែរ ។ ខ្លួនសូមបដិសេធ ការចោទប្រកាន់ ។ ឈ្មោះ [redacted] គីមហុង ត្រូវជាប្អូនថ្លៃរបស់ខ្លួន ។ ខ្លួនចាំរឿងហេតុខ្លះៗ ។ ខ្លួននៅផ្ទះ ជាមួយឈ្មោះ [redacted] សីហា ជាប៉ាក្មេក រស់នៅជាមួយឈ្មោះ [redacted] គីមហុង ដែរ ។ ខ្លួនមិនបាន ប៉ុនប៉ងចាប់រំលោភ ឈ្មោះ [redacted] គីមហុង ទេ ។ ថ្ងៃកើតហេតុខ្លួនឃើញជនរងគ្រោះ ដោយខ្លួនស្មានថា ជាប្រពន្ធរបស់ខ្លួន ទើបខ្លួនចូលទៅអោប នៅក្នុងបន្ទប់យាយ ។ ប្រពន្ធរបស់ខ្លួននិងឈ្មោះ [redacted] គីមហុង មាឌប៉ុនគ្នា ។ ខ្លួនបានចូលអោបម៉ោងជិត៥ភ្លឺ ។ ខ្លួននិងប្រពន្ធឈ្លោះគ្នាជាប្រចាំ ហើយថ្ងៃ កើតហេតុ ប្រពន្ធរបស់ខ្លួនពុំបានដេកក្នុងបន្ទប់ជាមួយខ្លួនទេ ។ ពេលនេះខ្លួនលែងលះគ្នាហើយ ទើបមានការប្តឹងផ្តល់ ។

-ជនរងគ្រោះឈ្មោះ [redacted] គីមហុង បានឆ្លើយថា ៖ ឈ្មោះ [redacted] ឧត្តម បានចូលក្នុងបន្ទប់ខ្លួន គេង តែឯង ម៉ោងជិត៥ភ្លឺ ។ ឈ្មោះ [redacted] ឧត្តម បានចាប់អោប ថើប ហើយបានខ្ទប់មាត់ខ្លួន កុំ ឱ្យស្រែក ហើយបានចាប់ស្រាតខោខ្លួន ។ ពេលយប់ខ្លួនគេងជាមួយយាយ ចំណែកឈ្មោះ [redacted] ឧត្តម គេងជាមួយប្រពន្ធរបស់គាត់ ត្រូវជាបងស្រីរបស់ខ្លួន ។ យប់កើតហេតុ ខ្លួនបានស្រែកដែរ តែមិនមាន អ្នកលឺ ដោយសារឈ្មោះ [redacted] ឧត្តម បានយកខ្នើយខ្ទប់មាត់ខ្លួន ។ ឈ្មោះ [redacted] ឧត្តម ចាប់ទាញខ្លួន ធ្លាក់ពីលើគ្រែ តែធ្លាក់តែជើង ហើយខ្លួនបានធាក់គាត់ ។ ខ្លួនដឹងថាជាឈ្មោះ [redacted] ឧត្តម ជាអ្នកចាប់ខ្លួន ដោយសារខ្លួនចាំក្លិនទឹកអប់ និងសំលេងរបស់គាត់ ដែលបានគំរាមខ្លួនថា កុំឱ្យ ស្រែក ។ ឈ្មោះ [redacted] ឧត្តម ចាប់ខ្លួនតែម្តង នេះទេ ។ ខ្លួននិយាយពិតទាំងអស់ ។ ឈ្មោះ [redacted] ឧត្តម បានយកប្រដាប់ភេទរបស់វា យកដាក់ឧលប្រដាប់ភេទរបស់ខ្លួនបានបន្តិច តែខ្លួនធាក់វាចេញ ។ ឈ្មោះ [redacted] ឧត្តម មិនបានរំលោភខ្លួនបានសម្រេចទេ ។

-ឈ្មោះ [redacted] ស៊ីដែន ជាម្តាយរបស់ជនរងគ្រោះ បានឆ្លើយថា ៖ ថ្ងៃកើតហាតុប្តីរបស់ខ្លួនមិននៅ ទេ គឺខ្លួននៅផ្ទះ តែខ្លួនមិនបានឃើញហេតុការណ៍ ដែលឈ្មោះ ឧត្តម ចាប់រំលោភកូនស្រីទេ តែ ក្រោយមកទើបកូនប្រាប់ ពីរឿងនេះ ។

-ជនរងគ្រោះឈ្មោះ [redacted] គីមហុង បានឆ្លើយថា ៖ ក្រោយកើតហេតុភ្លាមៗ ខ្លួនមិនបានរកអ្នក មកជួយទេ ខ្លួនគិតតែពីយំ ដោយខ្លួនភ័យ ។ ឈ្មោះ [redacted] ឧត្តម គំរាមខ្លួន ទើបខ្លួនមិនហ៊ានស្រែក ។

-ជនជាប់ចោទឈ្មោះ [redacted] ឧត្តម បានឆ្លើយថា ៖ ខ្លួនពិតជាបានចូលទៅអោបជនរងគ្រោះ មែន តែខ្លួនស្មានថាជាប្រពន្ធរបស់ខ្លួន ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សីហា បានឆ្លើយថា ៖ ពីមុនមក ខ្លួនព្រមអត់អោន ឱ្យហើយ តែម្តាយរបស់ឈ្មោះ [redacted] ឧត្តម បានជេរបរិហាកេរ្តិ៍ កូនស្រីរបស់ខ្លួន ទើបខ្លួនត្រូវតែ ប្តឹង ។ ខ្លួននៅតែទាមទារសំណងដដែល ។

-តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] គីមហុង បានឆ្លើយថា ៖ នៅថ្ងៃកើតហេតុនោះ ជនជាប់ចោទឈ្មោះ [redacted] ឧត្តម បានចូលក្នុងបន្ទប់របស់ខ្លួនតែម្នាក់ឯង ហើយបានធ្វើសកម្មភាពចាប់អោបថើបខ្លួន តែខ្លួនធាក់ជនជាប់ចោទ ទើបជនជាប់ចោទរំលោភមិនបានសម្រេច ។

-តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ឧត្តម បានឆ្លើយថា ខ្លួនពិតជាបានចូលក្នុងបន្ទប់របស់ជនរងគ្រោះឈ្មោះ [redacted] គីមហុង ប្រាកដមែន ។

-តាមចម្លើយរបស់ជនរងគ្រោះគ្រោះ និងចម្លើយរបស់ជនជាប់ចោទ បញ្ជាក់ឱ្យឃើញថា បើជនជាប់ចោទពិតជាមានបំណងចាប់រំលោភជនរងគ្រោះឱ្យបានសម្រេច មែននោះ ប្រាកដជាជនរងគ្រោះ មែនអាចគេចផុតបានឡើយ តែជនជាប់ចោទបានបញ្ឈប់សកម្មភាពរបស់ខ្លួនវិញ ដោយខ្លួនឯង ដោយត្រឹមតែបានអោបថើបលើជនរងគ្រោះតែប៉ុណ្ណោះ ។

-អំពើរបស់ជនជាប់ចោទដែលបានចាប់អោបថើបលើជនរងគ្រោះនោះ គឺជាអំពើ " ប្រទូសកេរខ្មាស " ពុំមែនជាអំពើ " ប៉ុនប៉ងរំលោភសេពសន្ថវៈ " ឡើយ ដែលអំពើរបស់ជនជាប់ចោទនេះមានភាពស៊ី សង្វាក់ទៅនឹងរបាយការណ៍សំយោគរបស់សមត្ថកិច្ច ផងដែរ ដែលបានធ្វើសេចក្តីសន្និដ្ឋានថា ជាករណី " ប្រទូសកេរខ្មាស " ។

-គ្មានភស្តុតាង និងពិរុទ្ធភាពគ្រាប់គ្រាន់លើឈ្មោះ [redacted] ឧត្តម ហៅ ហុង ភេទប្រុស អាយុ២១ឆ្នាំ (មានសាវតារជាតិដូចខាងលើ) ពីបទ " **ប៉ុនប៉ងរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ** " តាមបញ្ញត្តិមាត្រា ២៧ និងមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចភូមិបវេល១ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៧ ឡើយ តែមានភស្តុតាង និងពិរុទ្ធភាពគ្រាប់គ្រាន់លើឈ្មោះ [redacted] ឧត្តម ហៅ ហុង ភេទប្រុស អាយុ២១ឆ្នាំ (មានសាវតារជាតិដូចខាងលើ) ពីបទ " **ប្រទូសកេរខ្មាស** " តាមបញ្ញត្តិមាត្រា ២៤៦ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចភូមិបវេល១ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៧ ។

## ហេតុដូច្នេះសម្រេច

១-ទទួលពាក្យបណ្តឹងទាស់នឹងសាលក្រមព្រហ្មទណ្ឌលេខ ១១៧២ "ក" ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០ របស់លោក [redacted] ប៊ុនធឿន ជាមេធាវីការពារសិទ្ធិឱ្យពិរុទ្ធជនឈ្មោះ [redacted] ឧត្តម ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២០ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១១៧២ "ក" ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តបាត់ដំបង ទុកជាបានការដដែល លើកលែងតែចំណុចទី១ នៃ សេចក្តីសម្រេចដែលត្រូវសម្រេចសារជាថ្មី ដូចខាងក្រោម ៖

២-១-កែប្រែបទចោទប្រកាន់លើ ៖ ឈ្មោះ [redacted] ឧត្តម ហៅ ហុង ភេទប្រុស អាយុ២១ឆ្នាំ (មានសាវតារជាតិដូចខាងលើ) ពីបទ " **ប៉ុនប៉ងរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ** " តាមបញ្ញត្តិមាត្រា ២៧ និងមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចភូមិបវេល១ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៧ មកបទ " **ប្រទូសកេរខ្មាស** " តាមបញ្ញត្តិមាត្រា ២៤៦ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅ

35/1

ចំណុចភូមិបវេល១ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៧ ។

២-២-ផ្តន្ទាទោសដាក់ពន្ធនាគារលើ ៖ ឈ្មោះ [redacted] ឧត្តម ហៅ ហុង ភេទប្រុស អាយុ ២១ឆ្នាំ (មានសាវតារជាតិដូចខាងលើ) កំណត់រយៈពេល ០៣ឆ្នាំ(បីឆ្នាំ) គិតចាប់ពីថ្ងៃចាប់ខ្លួនបានយកមកអនុវត្តទោសក្នុងពន្ធនាគារ ពីបទ " ប្រទូសរកេរខ្មាស " តាមបញ្ញត្តិមាត្រា ២៤៦ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចភូមិបវេល១ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៧ ។

៣-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ ត្រូវនឹងថ្ងៃចន្ទ ១៤កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស២៥៦៤ ចំពោះមុខពិរុទ្ធជនឈ្មោះ [redacted] ឧត្តម ។

ទុកសិទ្ធិប្ដឹងឧទ្ធរណ៍ តាមកាលកំណត់នៃច្បាប់ ។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] |